# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ [illegible]

## សេចក្ដីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ថែទាំ និងផ្លាស់ប្ដូរបរិក្ខារប្រព័ន្ធបណ្ដាញចែកចាយ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដោយមូលហេតុដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី២៧ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិទួលគោក ភូមិទួលសង្កែ ក្នុងសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ភូមិទំនប់ ក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្ដាញផ្គត់ផ្គង់អគ្គិសនី ។

២. ថ្ងៃសុក្រទី២៨ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៤ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងលេខ P915, P1211 ស្ថិតនៅភូមិទួលគោក ក្នុងសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីកែលម្អបណ្ដាញផ្គត់ផ្គង់អគ្គិសនី ។

៣. ថ្ងៃសៅរ៍ទី២៩ ខែមីនា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នៅ (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិត្រពាំងឈូក ភូមិអូរបែកក្អម ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភូមិមានជ័យ ភូមិទ្រា៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ (២)តំបន់ភ្លើងលេខ P792 ស្ថិតនៅភូមិព្រៃទា ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៣)ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិប្រទះឡាង ភូមិព្រៃស្លឹ ភូមិថ្មី ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារបណ្ដាញផ្គត់ផ្គង់អគ្គិសនី ។

៤. ថ្ងៃអាទិត្យទី៣០ ខែមីនា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នៅតំបន់ភ្លើងលេខ PT890 ស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន និង (២)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិស្រែជំរៅ ភូមិដំណាក់ត្រយឹង ក្នុងសង្កាត់ចោមចៅ ភូមិកន្ទោក ភូមិអង្គត្រកៀត ក្នុងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្ដាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវេងស្រេង ។

៥. ថ្ងៃសៅរ៍ទី២៩ និងថ្ងៃអាទិត្យទី៣០ ខែមីនា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្ដោយផ្លូវវេងស្រេង ចាប់ពីភូមិទ្រា៣ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីរុះរើគន្លងខ្សែបណ្ដាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវេងស្រេង ។

អាស្រ័យហេតុនេះ សូមសម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ . ថ្ងៃទី...២៥...ខែ...មីនា...ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ_រតនៈ**